**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២០៤០ ព.ណ...ករា

ថ្ងៃអង្គារ ៩ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោកឧកញ៉ា លោក លោកស្រីជាពាណិជ្ជករ ផលិតផលករ និងសាធារណជនទូទៅដែលកំពុងធ្វើធុរកិច្ចក្នុងឧស្សាហកម្មម្ហូបអាហារ ឲ្យបានជ្រាបថា៖ ប្រទេសហុងគ្រី នឹងរៀបចំព្រឹត្តិការណ៍ពាណិជ្ជកម្ម ដ៏សំខាន់នៅអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត លើវិស័យឧស្សាហកម្មម្ហូបអាហារ (SIRHA Budapest Business Events of Food Industry ) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២២-២៤ ខែមីនា ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលតាំងពិព័រណ៍ និងសន្និសីទ HUNGEXPO ទីក្រុងប៊ុយដាប៉េស ប្រទេសហុងគ្រី។

SIRHA Budapest គឺជាព្រឹត្តិការណ៍ពាណិជ្ជកម្មនៃឧស្សាហកម្មម្ហូបអាហារដ៏សំខាន់នៅក្នុងតំបន់អឺរ៉ុប និងធ្លាប់រៀបចំឡើងទទួលបានជោគជ័យចាប់តាំងពីឆ្នាំ២០១៤កន្លងមក ដោយមានអ្នកចូលរួមដែលមានវិជ្ជាជីវៈផ្នែកម្ហូបអាហារចំនួន ២៤ ០០០ក្រុមហ៊ុនមកពី ៤៤ប្រទេស។ សម្រាប់ឆ្នាំ២០២២ខាងមុខព្រឹត្តិការណ៍នេះនឹងរៀបចំឡើងតាមទម្រង់កូនកាត់(Hybrid) ដោយមានការចូលរួមដោយផ្ទាល់ និងការចូលរួមតាំងបង្ហាញផលិតផលអនឡាញ និងមានការរៀបចំព្រឹត្តិការណ៍អមដូចជាជំនួបពាណិជ្ជកម្មតាមរយៈការចូលរួមដោយផ្ទាល់ និងចូលរួមតាមរយៈអនឡាញផងដែរ។

ដំណឹងនេះចាត់ទុកជាការអញ្ជើញលោកឧកញ៉ា លោក លោកស្រីដែលកំពុងធ្វើធុរកិច្ចក្នុងឧស្សាហកម្មម្ហូបអាហារដែលមានចំណាប់អារម្មណ៍ចង់ចូលរួមដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម និង/ឬមានបំណងសិក្សាស្វែងយល់ពីទីផ្សារម្ហូបអាហារនៅអឺរ៉ុបកណ្តាល អាចស្វែងរកព័ត៌មានបន្ថែមដោយចូលក្នុងគេហទំព័រ http://sirha-budapest.com/en/ ឬទំនាក់ទំនងសាកសួរព័ត៌មានបន្ថែមមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌ សែនសុខ រាជធានីភ្នំពេញ។

- ទូរស័ព្ទលេខ ៖ ០៩២ ៧៥៤ ២២២ ឬ ០៨៧ ៧៥៥ ៥៥១
- អ៊ីម៉ែល ៖ phonraya@yahoo.com / ritatong19@gmail.com

សូមអរគុណ !

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម